## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦២អនក្រ.បក ២០ កក្កដា ១៩៩៩

# អនុក្រឹត្យ
## ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ
## របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០២ ខែកក្កដា ឆ្នាំ១៩៩៩

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការរៀបចំបណ្តាអង្គភាពរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង កំណត់បេសកកម្មរបស់ក្រសួង និងមុខការរបស់បណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាននានា និងអង្គភាពមូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្ម អោយដឹកនាំនិងគ្រប់គ្រងការងារ រៀបចំដែនដីនគរូបនីយកម្មសំណង់សុរិយោដី និងភូមិសាស្ត្រ នៃព្រះរាជាណា- ចក្រកម្ពុជា លើកលែងតែតំបន់ណា ឬ សមត្ថកិច្ចណា ដែលរាជរដ្ឋាភិបាលប្រគល់អោយស្ថាប័នមួយផ្សេងទៀត។

**មាត្រា ៣.-**

ដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ច ដូចតទៅ :

១- ក្នុងបេសកកម្មរៀបចំដែនដី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ត្រូវ:

- លើកសំណើ និងដាក់អោយអនុវត្តនូវនយោបាយរៀបចំដែនដី ដែលធានាតុល្យភាព នៃកិច្ចអភិវឌ្ឍន៍ ទីក្រុង ជនបទ និង ការបែងចែកផលនៃការរីកចំរើន ។
- ធ្វើការសិក្សា និងការវិភាគសំរាប់អនាគតទាក់ទងនឹងការរៀបចំដែនដី ។ លើកសំណើនិងដាក់អោយអនុវត្តនូវលិខិតបទដ្ឋានចាំបាច់ទាំងឡាយ ក្នុងការអនុវត្តនយោបាយរៀបចំដែនដី។ លើកសំណើ នយោបាយ ផែនការសកម្មភាព និងវិធានការសមស្រប ដែលអនុគ្រោះដល់ការ អភិវឌ្ឍន៍ដែនដី ។
- យកចិត្តទុកដាក់ដល់ភាពសុខដុម នៃនយោបាយអភិវឌ្ឍន៍លើវិស័យនានា និងដល់ចំណង ផ្សារភ្ជាប់គ្នារវាងសកម្មភាព នៅថ្នាក់ក្រសួង និងថ្នាក់ខេត្ត-ក្រុង ។ ការងាររៀបចំដែនដី ជាការងារមានចរិតអន្តរវិស័យ ដែលទាមទារអោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយក្រសួងពាក់ព័ន្ធ ធ្វើជាសេនាធិការក្នុងការប្រមែប្រមូលទិន្នន័យ រូបវន្តទិន្នន័យ សេដ្ឋកិច្ច ទិន្នន័យសង្គមកិច្ច ប្រជាសាស្ត្រ..... ដើម្បីរៀបចំយុទ្ធសាស្ត្រកំណត់ តំបន់សំខាន់ៗដូចជាតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម តំបន់ ទីក្រុង តំបន់ជនបទ តំបន់អភិរក្សធម្មជាតិ តំបន់ទេសចរណ៍ តំបន់ការពារបេតិកភ័ណ្ឌ ព្រមទាំង ទីតាំងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច គមនាគមន៍ ទីតាំងរដ្ឋបាលសាធារណ: និងតំបន់ឯ ទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល
- អនុវត្តនយោបាយរៀបចំដែនដី ដែលមានភាពអនុគ្រោះដល់តំបន់ជនបទ និងតំបន់អាទិភាព របស់រាជរដ្ឋាភិបាល
- យកចិត្តទុកដាក់ចំពោះសេចក្តីសំរេច ស្តីពីការកសាងហេដ្ឋារចនាសម្ព័ន្ធ អោយស្របទៅតាម អាទិភាព នៃនយោបាយ រៀបចំដែនដី និងនយោបាយវិសហមជ្ឈការរដ្ឋបាល
- ជំរុញនយោបាយលើកទឹកចិត្ត ការវិនិយោគទៅរកតំបន់ជនបទ និង តំបន់អាទិភាពរបស់រាជ រដ្ឋាភិបាល ដោយសហការ ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និង ស្ថាប័នពាក់ព័ន្ធដទៃទៀត
- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គស្របតាមភារកិច្ចរបស់ក្រសួង ។

២- ក្នុងបេសកកម្មការងារនគរូបនីយកម្ម និងសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវ:

- ធ្វើការស្រាវជ្រាវ និង ការវិភាគសំរាប់អនាគត និងចងក្រងស្ថិតិទាំងឡាយទាក់ទងនឹងការងារនគរូបនីយកម្ម និងសំណង់។ លើកសំណើ និងដាក់អោយអនុវត្តនូវលិខិតបទដ្ឋានចាំបាច់ ទាំងឡាយក្នុងការអនុវត្តនយោបាយ នគរូបនីយកម្ម និងសំណង់ ។
- លើកសំណើនយោបាយ ផែនការសកម្មភាព និងវិធានការសំរាប់ការដោះស្រាយសំណង់ អនាធិបតេយ្យ និងការសាងសង់ លំនៅដ្ឋានដោយរក្សាទេសភាព រមណីយដ្ឋាន នៅក្នុងទីក្រុង និងទីប្រជុំជន ជនបទ និងការពារបរិស្ថាន។
- កំណត់វិធានទាំងឡាយនិងរៀបចំបទបញ្ញាទាក់ទងនឹងការកាន់កាប់ដីធ្លី នគរូបនីយកម្ម សំណង់ អស្សាមិករណ៏ ការកំណត់ដីបំរុង
- ចេញលិខិតអនុញ្ញាត និង ការយល់ព្រមទាំងឡាយទាក់ទងនឹងនគរូបនីយកម្ម និងសំណង់
- ជំរុញការសាងសង់លំនៅដ្ឋាន សង្គមកិច្ច ធ្វើប្រតិបត្តិការរៀបចំទីក្រុង ធ្វើការបែងចែក ដីជាឡូតិ៍ជាតំបន់អភិវឌ្ឍន៍
- យកចិត្តទុកដាក់ដល់ការសាងសង់ និង ការថែទាំអគារសាធារណៈ
- រួមជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីការពារបេតិកភ័ណ្ឌ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ
- រួមជាមួយអាជ្ញាធរអប្សរា ដើម្បីការពារបេតិកភ័ណ្ឌ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ ក្នុងតំបន់ ជាសមត្ថកិច្ចរបស់អាជ្ញាធរ
- រួមជាមួយក្រសួងបរិស្ថាន ដើម្បីថែរក្សាការពារបរិស្ថាន ទេសភាព រមណីយដ្ឋានធម្មជាតិ និងប្រព័ន្ធអេកូ។

៣- ក្នុងបេសកកម្មការងារសុរិយោដី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់មានភារកិច្ច ធ្វើការស្រាវជ្រាវ កសាងលិខិតបទដ្ឋានទាំងឡាយ ដែលទាក់ទងនឹងការងារគ្រប់គ្រងប្រើប្រាស់ដីធ្លីតាមប្រព័ន្ធពតិមានវិទ្យា ។ ធ្វើការវាស់វែងគូរប្លង់សុរិយោដី និងចេញប័ណ្ណសំគាល់សិទ្ធិលើដីធ្លីទូទាំង ព្រះរាជាណាចក្រកម្ពុជា ធ្វើការងារ អភិរក្ស សុរិយោដី ។

៤- ក្នុងបេសកកម្មការងារភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ច គ្រប់គ្រង និងផ្សព្វផ្សាយផែនទី ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដែលផលិតផែនទីជំនាញ ដើម្បីអោយផែនទីទាំងអស់ ប្រើប្រាស់ប្រព័ន្ធ ពតិមានភូមិសាស្ត្រឯកភាពគ្នា។

៥- គ្រប់គ្រង ត្រួតពិនិត្យ កំណត់សមត្ថភាពបច្ចេកទេសវិជ្ជាជិវៈនិង ចេញលិខិតអនុញ្ញាតអាជីវកម្ម ដល់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើអាជីវកម្មទាក់ទងនឹងលំនៅដ្ឋាន ការប្រើប្រាស់ដីធ្លីការ សាងសង់ និងការសិក្សា ធ្វើគំរោងប្លង់។

៦- តំរង់ទិសណែនាំ តាមដានត្រួតពិនិត្យរាល់កិច្ចការ លើវិស័យរៀបចំដែនដីនគរូបនីយកម្មសំណង់ សុរិយោដី និងភូមិសាស្ត្រ។

៧- ផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល ច្បាប់ បទប្បញ្ញត្តិ និង បច្ចេកទេសវិជ្ជាជីវៈ ដែលទាក់ទងនឹងវិស័យរៀបចំដែនដី នគរូបនីយកម្មសំណង់ សុរិយោដី និង ភូមិសាស្ត្រ ។

៨- ធ្វើសហប្រតិបត្តិការជាមួយអន្តរជាតិ និង អង្គការនានា ដើម្បីដំណើរការល្អនៃវិស័យរៀបចំដែនដីនគរូបនីយកម្ម សំណង់សុរិយោដី និងភូមិសាស្ត្រ ។

៩- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការប្រមូលពន្ធពីបេតិកភ័ណ្ឌ ។

**មាត្រា ៤.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរចនាសម្ព័ន្ធដូចតទៅ :

១- ថ្នាក់កណ្តាល :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាលរួមមាន:
    - នាយកដ្ឋានរដ្ឋបាល និង កិច្ចការទូទៅ
    - នាយកដ្ឋានបុគ្គលិក
    - នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច
    - នាយកដ្ឋាននីតិកម្ម
    - នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និង ទំនាក់ទំនងអន្តរជាតិ
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មរួមមាន:
    - នាយកដ្ឋានស្រាវជ្រាវ និង បទប្បញ្ញត្តិ
    - នាយកដ្ឋានរៀបចំដែនដី
    - នាយកដ្ឋាននគរូបនីយកម្ម
- អគ្គនាយកដ្ឋានសំណង់រួមមាន:
    - នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់
    - នាយកដ្ឋានសិក្សាគំរោងប្លង់
    - នាយកដ្ឋានសំណង់
- អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ រួមមាន:
    - នាយកដ្ឋានគ្រប់គ្រងដីធ្លី
    - នាយកដ្ឋានអធិការកិច្ចភូមិបាល
    - នាយកដ្ឋានបច្ចេកទេស
    - នាយកដ្ឋានអភិរក្សសុរិយោដី

• នាយកដ្ឋានភូមិសាស្ត្រ

- មន្ទីរពិសោធន៍
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រឹះស្ថាន និង សហគ្រាសក្រោមឱវាទ
- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

២- អង្គការមូលដ្ឋានៈ

- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង
- ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ភូមិបាល ខ័ណ្ឌ ស្រុក អង្គការលេខ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

## ជំពូកទី ៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៥.-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី ៤

## អធិការដ្ឋាន

**មាត្រា ៦.-**

អធិការដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារ :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាព ក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- ធ្វើរបាយការណ៍ជាប្រចាំជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ច ហើយ និងអំពីមធ្យោបាយកែលំអការប្រព្រឹត្តទៅអង្គភាពនោះ
- ពិនិត្យ សម្រុះសម្រួល និងដោះស្រាយវិវាទរដ្ឋបាល ដែលពាក់ព័ន្ធដល់សមត្ថកិច្ច និងសកម្មភាព របស់មន្ត្រី និង ភ្នាក់ងាររបស់ក្រសួង
- ប្រតិបត្តិកិច្ចការតាមការដែលរដ្ឋមន្ត្រីបានប្រគល់ជូន
- អធិការដ្ឋានដឹកនាំដោយអធិការមួយរូប និង អមដោយអធិការរងជាជំនួយការតាមការចាំបាច់។

## ជំពូកទី ៥

## អគ្គនាយកដ្ឋានរដ្ឋបាល

**មាត្រា ៧.-**

អគ្គនាយកដ្ឋានរដ្ឋបាល មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារៈ

- គ្រប់គ្រងការងារ ដូចជា : រដ្ឋបាល បូកសរុបរបាយការណ៍ ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ សំភារៈបរិក្ខារ ក្របខ័ណ្ឌ ក្រសួងនិងការងារសិក្សា ស្រាវជ្រាវនីតិកម្ម
- សំរបសំរួលរាល់សកម្មភាពរដ្ឋបាលក្នុងក្រសួងជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត-ក្រុង និងជាមួយប្រទេស ស្ថាប័ននានា
- រៀបចំកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និង វិនិយោគ ស្របតាមនយោបាយរៀបចំដែនដីនគរូប នីយក ម្ម និង សំណង់ ដោយសហការ ជាមួយក្រសួង អង្គការ ស្ថាប័នជាតិ និង អន្តរជាតិ
- ធ្វើទំនាក់ទំនងជាមួយសាធារណជន និង អន្តរជាតិ

អគ្គនាយកដ្ឋានរដ្ឋបាល ដឹកនាំដោយអគ្គនាយកមួយរូប និង មានអគ្គនាយករងជាជំនួយការ តាមការ ចាំបាច់ ។ អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ៥ គឺ :

- នាយកដ្ឋាន រដ្ឋបាល និង កិច្ចការទូទៅ
- នាយកដ្ឋាន បុគ្គលិក
- នាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- នាយកដ្ឋាន នីតិកម្ម
- នាយកដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និង ទំនាក់ទំនងអន្តរជាតិ ។

**មាត្រា ៨.-**

**នាយកដ្ឋានរដ្ឋបាល និង កិច្ចការទូទៅមានតួនាទី និង ភារកិច្ចដូចតទៅ:**

- សំរបសំរួលសកម្មភាពការងារគ្រប់ផ្នែក របស់ក្រសួងនៅថ្នាក់កណ្តាល រវាងថ្នាក់កណ្តាល និងអង្គភាព មូលដ្ឋានចំណុះក្រសួង
- កសាងផែនការការងាររបស់ក្រសួង
- គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់ក្រសួង
- រៀបចំខ្លឹមសារប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា និង ពិធីបុណ្យផ្សេងៗ
- ធានាប្រសិទ្ធិភាព សុវត្ថិភាពរដ្ឋបាល ក្នុងទីស្តីការក្រសួង
- បូកសរុប និងធ្វើរបាយការណ៏ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង
- ធ្វើទំនាក់ទំនងអន្តរក្រសួង និង សាធារណជន
- សរុបពត៌មានអត្ថបទសារពត៌មាន ដែលពាក់ព័ន្ធដល់ក្រសួង នាយកដ្ឋានរដ្ឋបាលដឹកនាំដោយប្រធាន មួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៩.-**

**នាយកដ្ឋានបុគ្គលិក មានតួនាទី និង ភារកិច្ចដូចតទៅ:**

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈរបស់ក្រសួង ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- រៀបចំលិខិតរដ្ឋបាល សំរាប់គ្រប់គ្រងអាជីព
- ធ្វើកម្មវិធីអំពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតំលៃតំរូវការ ក្នុងការបណ្តុះបណ្តាលបុគ្គលិក
- តាមដាន វាយតំលៃ សមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការក្នុងក្រសួង
- រៀបចំការងារបៀវត្ស ពលកម្ម ប្រាក់កំរៃ និង គ្រប់គ្រងការងារសង្គមរបស់ក្រសួង
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ។

នាយកដ្ឋានបុគ្គលិកដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា ១០.-**

**នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច មានតួនាទី និងភារកិច្ចដូចតទៅ:**

- សហការសំរបសំរួលជាមួយបណ្តានាយកដ្ឋាន អង្គភាព មន្ទីរចំណុះក្រសួង ដើម្បីកសាងផែនការចំណូលចំណាយ ថវិការបស់ក្រសួង និង មន្ទីរខេត្ត-ក្រុង
- ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុបង់ចូលថវិការដ្ឋ
- ប្រមូលផ្តុំ និង កែតំរូវជំពូកថវិកាហិរញ្ញវត្ថុ
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់ ក្រសួង និងខេត្ត-ក្រុង។
- ទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឬស្ថាប័ននានាដែលពាក់ព័ន្ធ និងធ្វើការចំណាយ ថវិកាថវិកា បំរើកិច្ចប្រតិបត្តិការរបស់ក្រសួង និង ខេត្ត-ក្រុង
- ចូលរួមពិនិត្យ គុណភាពបរិមាណរាល់មុខសំភារៈ ឧបករណ៏ដែលត្រូវបញ្ចូលឃ្លាំង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយលើមធ្យោបាយធ្វើដំណើរ និង ដឹកជញ្ជូន
- ធ្វើកិច្ចបញ្ជាការជាប្រចាំនូវសលាប័ត្រ និងគណនេយ្យរូបធាតុ
- ពតិមានវិទ្យាសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃប្រតិបត្តិលទ្ធកម្ម សាធារណៈ
- រៀបចំ និង គ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ក្រសួង និង កំណត់កម្មវិធីចំណាយអភិវឌ្ឍន៏សេដ្ឋកិច្ចលើគ្រប់ផ្នែកទាំងអស់

- សិក្សា និង វាយតំលៃលើផ្នែកហិរញ្ញវត្ថុ និងផ្នែកសេដ្ឋកិច្ចលើគំរោងការខាងវិនិយោគ ដែលមានប្រភពចំណាយក្នុង ឬក្រៅប្រទេសក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍
- សំរបសំរួលជំនួយពីបរទេស និង ត្រួតពិនិត្យការអនុវត្តន៍
- ណែនាំការងារជំនាញ ផែនការដល់គ្រប់បណ្តាអង្គភាពខេត្ត-ក្រុង ដែលយកថវិការបស់ក្រសួងទៅប្រើប្រាស់ តាមគោលការណ៍ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍បូកសរុបការងារប្រចាំឆមាស និងប្រចាំឆ្នាំ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១១.-**

**នាយកដ្ឋាននីតិកម្ម មានតួនាទី និងភារកិច្ច ដូចតទៅ:**

- ជាសេនាធិការរបស់ក្រសួងក្នុងកិច្ចការនីតិកម្ម
- កសាងសេចក្តីព្រាងច្បាប់ អនុក្រឹត្យ ប្រកាស សារាចរ បទបញ្ជា លិខិតបទដ្ឋាន និងឯកសារផ្សេងៗទៀតរបស់ក្រសួង
- ពិនិត្យកែសំរួលអត្ថបទច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន របស់នាយកដ្ឋាន និងបណ្តាអង្គភាពមន្ទីរចំណុះអោយ ស្របតាមច្បាប់ជាធរមាន
- ផ្តល់យោបល់ផ្នែកគតិយុត្តដល់បណ្តានាយកដ្ឋាន អង្គភាព មន្ទីរចំណុះ ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនអោយ សមស្រប
- ចូលរួមបណ្តុះបណ្តាលផ្សព្វផ្សាយច្បាប់ និង លិខិតបទដ្ឋាន ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ
- ពិនិត្យ និង ផ្តល់យោបល់ អំពីលក្ខណៈគតិយុត្តលើសំណុំលិខិតអនុញ្ញាតកាន់កាប់ដីធ្លី សំណុំលិខិតសុំអនុញ្ញាតសាងសង់ សំណុំលិខិតធ្វើអាជីវកម្មសិក្សាគំរោងប្លង់ សំណុំលិខិតសុំអនុញ្ញាតធ្វើអាជីវកម្មសាងសង់ សំណុំលិខិត សុំអនុញ្ញាតបើក និងបិទការដ្ឋានសាងសង់ ដែលស្ថិតនៅក្នុងថ្នាក់កណ្តាល
- សហការជាមួយអធិការដ្ឋាន របស់ក្រសួងក្នុងការអង្កេតនូវរាល់ការអនុវត្តច្បាប់ និងដោះស្រាយ វិវាទដែលពាក់ព័ន ដីធ្លី និងសំណង់
- គ្រប់គ្រងបណ្ណាល័យសំរាប់ក្រសួង ។

នាយកដ្ឋាននីតិកម្មដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១២.-**

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និង ទំនាក់ទំនងអន្តរជាតិ មានតួនាទី និង ភារៈកិច្ចដូចតទៅ :

- រៀបចំកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិនិយោគ ស្របតាមនយោបាយរៀបចំដែនដី និងនគរូបនីយកម្ម ដោយធ្វើទំនាក់ទំនងជាមួយបណ្តាអ្នកផ្តល់ទុនជាប្រាក់ខ្ចី ឬជាជំនួយអន្តរជាតិ អ្នកវិនិយោគទុន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទីស្តីការ គណៈរដ្ឋមន្ត្រី
- វិភាគបណ្តាគំរោងវិនិយោគទុន អំពីគុណភាព និងចំណុចខ្វះខាត ឬភាពមិនប្រក្រតីរបស់គំរោងក្នុងកិច្ចអភិវឌ្ឍន៍ សេដ្ឋកិច្ចរបស់ខេត្ត-ក្រុង
- តាមដានការអនុវត្តន៍គំរោងដែលបានអនុម័តហើយ
- សំរបសំរួលជំនួយបរទេស
- ធ្វើផែនការទំនាក់ទំនងបរទេស
- ធ្វើជាសេនាធិការអោយក្រសួង ក្នុងការធ្វើទំនាក់ទំនង សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងធ្វើសហប្រតិបត្តិការអន្តរជាតិ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៦
## អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

**មាត្រា ១៣.-**

អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារ :

- លើកសំណើ និងអនុវត្តនយោបាយយុទ្ធសាស្ត្រ រៀបចំដែនដី និងនគរូបនីយកម្ម ដើម្បីអភិ វឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ប្រកបដោយតុល្យភាព និងចីរភាព សំដៅការពារផលប្រយោជន៍ទូទៅ និងធ្វើអោយមានសណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ការពារបរិស្ថាន ការពារធនធាន ធម្មជាតិសម្បត្តិវប្បធម៌ និងបេតិកភ័ណ្ឌ
- ចងក្រងពត៌មាន ទិន្នន័យ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាវិភាគសំរាប់អនាគត រៀបចំកសាងគោលនយោបាយ ផែនការ កម្មវិធី នីតិវិធី ច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន ស្តង់ដារ និងវិធានការ ដែលទាក់ទងនឹងការរៀបចំដែនដី និង នគរូបនីយកម្ម
- ណែនាំ តាមដាន ត្រួតពិនិត្យ និង ជំរុញការអនុវត្តនយោបាយរៀបចំដែនដី និងនគរូបនីយកម្ម អោយបានសមស្របទូទាំងប្រទេស
- ពិនិត្យគំរោងស្នើសុំទីតាំងសាងសង់
- លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និង បណ្តាមន្ទីរខេត្ត-ក្រុង
- សហការជាមួយអង្គការអន្តរជាតិ និង អង្គការនានា ។

អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមចាំបាច់ ។

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ៣ ដូចតទៅ :

- នាយកដ្ឋានស្រាវជ្រាវ និង បទប្បញ្ញត្តិ
- នាយកដ្ឋានរៀបចំដែនដី
- នាយកដ្ឋាននគរូបនីយកម្ម

**មាត្រា ១៤.-**

នាយកដ្ឋានស្រាវជ្រាវ និង បទប្បញ្ញត្តិ មានតួនាទី និងភារកិច្ចដូចតទៅ :

- ធ្វើទំនាក់ទំនង សហការជាមួយក្រសួង ស្ថាប័ន និងបណ្តាខេត្ត-ក្រុង ដើម្បីស្រាវជ្រាវប្រមូល ពត៌មាន ស្ថិតិ ទិន្នន័យ សំរាប់ជាមូលដ្ឋាន ក្នុងការចងក្រងច្បាប់ស្តីពីការគ្រប់គ្រង ប្រើប្រាស់ដីធ្លី អស្សាមិករណ៍ កំណត់ដីបំរុង និងធ្វើសេចក្តីណែនាំ សារាចរបទប្បញ្ញត្តិ លិខិតបទដ្ឋាន ដែលទាក់ទងនឹងការរៀបចំដែនដី និងនគរូបនីយកម្ម
- ត្រួតពិនិត្យ ផលប៉ះពាល់នយោបាយរៀបចំដែនដី និង នគរូបនីយកម្ម ដែលបណ្តាលមកពីគំរោងវិនិយោគក្នុង និង ក្រៅប្រទេស
- កំណត់លក្ខណៈវិនិច្ឆ័យទីតាំង និងប្រភេទអាជីវកម្មនៃគំរោងអភិវឌ្ឍន៍ ដែលប្រើប្រាស់ ហិរញ្ញវត្ថុជាតិ អន្តរជាតិ រដ្ឋ និងឯកជន។

នាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា ១៥.-**

**នាយកដ្ឋានរៀបចំដែនដី មានតួនាទី និង ភារកិច្ច ដូចតទៅ :**

- រៀបចំគោលនយោបាយផែនការ និងយុទ្ធសាស្ត្ររៀបចំដែនដី ធានាការប្រើប្រាស់ដីធ្លី ធនធាន ធម្មជាតិ អោយបានសមស្របប្រកបដោយតុល្យភាព និងចីរភាព
- រៀបចំឯកសារបច្ចេកទេសសំរាប់ការប្រជុំអន្តរក្រសួង
- ធ្វើសេនាធិការជូនក្រសួងក្នុងការកសាងនីតិវិធី សំរាប់ធ្វើសេមាថ្នាក់ជាតិ សេមាតាមវិស័យ សេមាថ្នាក់តំបន់ និងថ្នាក់ខេត្ត-ក្រុង
- ធ្វើវិភាគសំរាប់អនាគត និងកសាងទំរង់គំរោង ផែនការ កម្មវិធីក្នុងការរៀបចំកែលំអបណ្តាញហេដ្ឋារចនាសម្ព័ន្ធ កំរិតជាតិដើម្បីអភិវឌ្ឍន៍ដោយសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក្នុងការកំណត់បណ្តាញគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ អាងទឹកកំពង់ផែ អាកាសយានដ្ឋាន និង កំណត់ការរៀបចំដែនដីចែកជាតំបន់សំខាន់ៗ ដូចជាៈ តំបន់ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្មលំនៅដ្ឋាន ទេសចរណ៍ និង តំបន់ធម្មជាតិដូចជាៈ ព្រៃ ភ្នំ បឹង ជ្រោះ ទន្លេ សមុទ្រ ឆ្នេរសមុទ្រ តំបន់រក្សាទុកជាដើម
- តាមដានការអនុវត្តការងាររបស់បណ្តាក្រសួង និងអាជ្ញាធរដែនដីខេត្ត-ក្រុង ទាក់ទងនឹងការ រៀបចំដែនដី អោយស្របតាមអាទិភាពដែលបានកំណត់ក្នុងក្របខ័ណ្ឌនយោបាយរៀបចំដែនដី

- តាមដានកត់ត្រាជាប្រចាំរាល់ទិន្នន័យសេដ្ឋកិច្ចសង្គមលើគំរោងផែនទីជាតិ។

នាយកដ្ឋានរៀបចំដែនដី ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាម ការចាំបាច់។

**មាត្រា ១៦.-**

**នាយកដ្ឋាននគរូបនីយកម្ម មានតួនាទី និង ភារកិច្ច ដូចតទៅ :**

- លើកសំណើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន ស្តីពីនគរូបនីយកម្ម
- អនុវត្តនយោបាយនគរូបនីយកម្ម ដើម្បីអភិវឌ្ឍន៍ទីក្រុង តំបន់ជុំវិញទីក្រុង ទីប្រជុំជនជនបទ និងតំបន់ផ្សេងៗ ទៀតដែលជះឥទ្ធិពលលើទីក្រុង ដើម្បីលើកស្ទួយសណ្តាប់ធ្នាប់សង្គម សោភ័ណភាព សុវត្ថិភាព និង សុខុមាលភាព
- សិក្សារៀបចំប្លង់មេ និងប្លង់លំអិត ដោយបែងចែកទីក្រុង និងតំបន់ជុំវិញទីក្រុង ជាតំបន់សំរាប់ទីតាំងមជ្ឈមណ្ឌលពាណិជ្ជកម្ម សិប្បកម្ម រដ្ឋបាល ទីតាំងសំរាប់សកម្មភាពអប់រំ លំនៅស្ថាន ដីបំរុង សាលារៀន ទីលានកីឡា ចំណីសងខាង ផ្លូវសាធារណៈ ទីលំហែកាយ មន្ទីរពេទ្យ ទីសក្ការះបូជា វត្តអារាម សួនច្បារសាធារណៈជាដើម។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំគំរោងបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ប្រព័ន្ធធ្វើដំណើរសាធារណៈ បណ្តាញលូទឹកស្អុយ បណ្តាញទឹកស្អាត អគ្គីសនី ទូរគមនាគមន៍ និងបណ្តាញផ្សេងៗ ទៀតសំរាប់តំរូវការក្នុងក្រុង
- រៀបចំកែលំអគុណភាពទីក្រុង និង តំបន់ថ្មី ក្នុងទីក្រុង
- រៀបចំគំរោងបង្កើតទីក្រុងថ្មី និង តំបន់អភិវឌ្ឍន៍សហគមន៍ថ្មី
- តាមដានកត់ត្រា វិភាគទិន្នន័យ សេដ្ឋកិច្ច សង្គម សមត្ថភាពផ្គត់ផ្គង់ ដឹកជញ្ជូន ស្ថិតិជំរឿនដង់ស៊ីតេកំណើន ប្រជាជន និងកត្តាផ្សេងៗទៀត ដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍន៍ទីក្រុង។
- ពិនិត្យ និង ផ្តល់លិខិតអនុញ្ញាតសាងសង់
- ត្រួតពិនិត្យ និង មានវិធានការសំរាប់អនុវត្តនយោបាយនគរូបនីយកម្មអោយមានប្រសិទ្ធភាព។

នាយកដ្ឋាននគរូបនីយកម្ម ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាម ការចាំបាច់។

## ជំពូកទី ៧

## អគ្គនាយកដ្ឋានសំណង់

**មាត្រា ១៧.-**

អគ្គនាយកដ្ឋានសំណង់ មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារ

- លើកស្ទួយខឿនស្ថាបត្យកម្មក្នុងវិស័យសំណង់អោយមានលក្ខណៈជាតិ និង ទំនើបទាន់សម័យ

- ស្រាវជ្រាវ រៀបចំ បទប្បញ្ញត្តិ ទំរង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេស ផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងស្តង់ដារសំភារៈបរិក្ខារ សំណង់អោយបានឯកភាព
- តម្រង់ទិស ណែនាំ តាមដានត្រួតពិនិត្យការសាងសង់ការជួសជុល ការថែទាំ ការរុះរើរាល់ បណ្តាគំរោងសំណង់អាគាររបស់រដ្ឋ ឯកជន អង្គការនានា រួមទាំងសំណង់បេតិកភ័ណ្ឌ និង សំណង់ផ្សេងៗទៀត។ សំណង់ផ្សេងៗទៀតនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង។
- គ្រប់គ្រងពិនិត្យកំណត់សមត្ថភាពបច្ចេកទេសវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាតអាជីវកម្ម ដល់ រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងទៅនិងការសាងសង់ និងការសិក្សាគំរោងប្លង់
- ត្រួតពិនិត្យ និង ដាក់អោយធ្វើការពិសោធន៍ សំភារៈសំណង់
- កំណត់ស្តង់ដារ គុណភាព សំភារៈ បរិក្ខារសំណង់ ដែលនាំចូលមកពីបរទេស និង ផលិតក្នុងប្រទេស
- លើកផែនការបណ្តុះបណ្តាល ជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និង បណ្តាមន្ទីខេត្ត-ក្រុង និងធ្វើទំនាក់ទំនង ណែនាំបច្ចេកទេសដល់បណ្តាគ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និង ស្ថាបត្យកម្ម
- សំរបសំរួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ដើម្បីត្រួតពិនិត្យបណ្តាគំរោងវិនិយោគសំណង់

អគ្គនាយកដ្ឋានសំណង់ ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជំនួយការតាមការ ចាំបាច់។

អគ្គនាយកដ្ឋានសំណង់ មាននាយកដ្ឋានចំណុះចំនួន ៣ :

- នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់
- នាយកដ្ឋានសិក្សាគំរោងប្លង់
- នាយកដ្ឋានសំណង់

**មាត្រា ១៨.-**

**នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ មានតួនាទីនិងភារកិច្ចដូចតទៅៈ**

- ស្រាវជ្រាវកសាង បទប្បញ្ញត្តិ ទំរង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែក សំណង់ និង ស្ថាបត្យកម្ម រួមទាំងសំភារៈបរិក្ខារសំណង់
- កំណត់ស្តង់ដារ ប្រភេទ សំភារៈ បរិក្ខាសំណង់ និង លក្ខណៈវិនិច្ឆ័យបច្ចេកទេស គុណភាពការងារសំណង់ និងចូលរួមផ្តល់យោបល់ អំពីគុណភាពសំណង់ តំរូវការគុណភាព សំភារៈបរិក្ខារ គ្រឿងចក្រសំណង់ដែលនាំចូល ពីបរទេសតាមការផ្លាស់ប្តូរពាណិជ្ជកម្ម និង ផលិតក្នុងស្រុក
- ចងក្រងបណ្តាបញ្ជីតំលៃសំភារៈសំណង់ គ្រឿងចក្រសំណង់ និងពលកម្ម ដែលប្រែប្រួល តាមខេត្ត-ក្រុង និងតាមដានជាប្រចាំនូវការប្រែប្រួលថ្លៃនៅតាមទីផ្សារទាំងនោះ
- ត្រួតពិនិត្យនិងដាក់អោយធ្វើការពិសោធន៍សំភារៈ គ្រឿងផ្គុំសំណង់ ដី ព្រមទាំងស្រាវជ្រាវ បង្កើតមុខសំភារៈ សំណង់ថ្មីៗ ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងប្រទេស បំរើអោយលំនៅដ្ឋាន របស់ប្រជាពលរដ្ឋ។ ស្រាវជ្រាវជាប្រចាំ សំភារៈផលិតចេញថ្មីៗ គ្រឿងចក្របរិក្ខាបំរើអោយ ការងារសាងសង់ទំនើបៗ លើទីផ្សារជាតិនិងអន្តរជាតិ

- សហការជាមួយនាយកដ្ឋានបុគ្គលិក និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលជំនាញ បច្ចេកទេស ដល់បុគ្គលិកក្រសួង និង បណ្តាមន្ទីខេត្ត-ក្រុង។ ចាត់ចែងអប់រំ ផ្សព្វផ្សាយឯកសារ បច្ចេកទេស សំណង់ដល់គ្រប់មជ្ឈដ្ឋាន ដើម្បីលើកស្ទួយប្រសិទ្ធភាពសេដ្ឋកិច្ច សុវត្ថិភាព និងសុមាលភាពសាធារណៈ ព្រមទាំងណែនាំបច្ចេកទេសដល់គ្រឹះស្ថាន បណ្តុះបណ្តាល មុខវិជ្ជាសំណង់ និង ស្ថាបត្យកម្ម។

នាយកដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា ១៩.-**

**នាយកដ្ឋានសិក្សាគំរោងប្លង់ មានតួនាទីនិងភារកិច្ច ដូចតទៅ :**

- សិក្សាគំរោងប្លង់សាងសង់ថ្មី ជួសជុល កែលំអពង្រីកបើកទូលាយអគាររបស់បណ្តាក្រសួងស្ថាប័ន និង អាជ្ញាធរ ដែនដីខេត្ត-ក្រុង ដែលប្រើប្រាស់ថវិការបស់ ឯកជនអង្គការនានា អ្នកវិនិយោគទុន ក្នុងប្រទេសឬក្រៅប្រទេស និងអង្គការអន្តរជាតិ។ សិក្សាស្រាវជ្រាវធ្វើគំរោងប្លង់ ដែលចែក ចេញជាផ្នែកឯកសារបច្ចេកទេស ស្ថាបត្យកម្ម និង ផ្នែកគំនូរប្លង់។
- សិក្សាស្រាវជ្រាវគំរោងប្លង់ និង ធ្វើបញ្ជីប៉ាន់ស្មានសំភារៈ នៃគំរោងសំណង់សាធារណៈ។
- ត្រួតពិនិត្យគំរោងប្លង់ស្ថាបត្យកម្ម និង បច្ចេកទេសសំណង់អគារ
- ត្រួតពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់
- ត្រួតពិនិត្យបណ្តាគំរោងប្លង់ អ្នកវិនិយោគនានា អំពីតំរូវការពិតនៃសំភារៈសំណង់នាំចូល ជារូបិយប័ណ្ណ
- គ្រប់គ្រង ត្រួតពិនិត្យ និង កំណត់សមត្ថភាពបច្ចេកទេស និង ចេញលិខិតអនុញ្ញាតបើក អាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងនឹងការសិក្សាធ្វើគំរោងប្លង់ និងការសាងសង់។

នាយកដ្ឋានសិក្សាគំរោង ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាម ការចាំបាច់។

**មាត្រា ២០.-**

**នាយកដ្ឋានសំណង់ មានតួនាទី និង ភារកិច្ច ដូចតទៅ :**

- ណែនាំ តាមដាន ត្រួតពិនិត្យ រាល់ការងារបច្ចេកទេសក្នុងការសាងសង់ វុះរើតាមតំណាក់ កាលនីមួយៗ ដើម្បីធានា សុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ គុណភាពសំណង់
- ចេញលិខិតអនុញ្ញាតបើក និង បិទការដ្ឋានរបស់បណ្តាសហគ្រាស ក្រុមហ៊ុន អង្គភាព សាងសង់ នានា
- ចូលរួមធ្វើកោសល្យវិច័យនានា ផ្តល់សំណុំឯកសារបច្ចេកទេសដល់ស្ថាប័នមានសមត្ថកិច្ច ក្នុងករណីវិវាទបញ្ហាសាងសង់ វុះរើបាក់ស្រុត និងករណីបទល្មើសផ្សេងទៀត ដែលផ្ទុយនឹងបទដ្ឋាន បច្ចេកទេស
- សិក្សាលើបច្ចេកទេសសាងសង់ទំនើប រឹងមាំ មានប្រសិទ្ធិភាព ជាសកល និងឆាប់រហ័ស ដែលកំពុងត្រូវប្រើប្រាស់ នៅប្រទេសនានាពិសេសបណ្តាប្រទេសអាស៊ាន
- រៀបចំបទប្បញ្ញត្តិ សេចក្តីណែនាំក្នុងការជួសជុលថែទាំ ប្រើប្រាស់សំណង់អាគារសាធារណៈ និងបេតិកភ័ណ្ឌ

- តាក់តែងកម្មវិធី និង កសាងគំរោងថវិការជួសជុល ថែទាំធំៗ ព្រមទាំងធានាអំពីលក្ខណៈបច្ចេកទេសសំណង់តាមកិច្ចសន្យា
- ស្រង់ស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច តំលៃវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈ និងបេតិកភ័ណ្ឌ
- ណែនាំត្រួតពិនិត្យរាល់ការងារបច្ចេកទេស ក្នុងការជួសជុលកែសំរួល ដើម្បីធានាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ប្រសិទ្ធភាព សេដ្ឋកិច្ច សោភ័ណភាព គុណភាពសំណង់ នៃគ្រប់បណ្តាសំណង់សាធារណៈ និងគ្រប់បណ្តាសំណង់បេតិកភ័ណ្ឌ។

នាយកដ្ឋានសំណង់ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាមការចាំបាច់។

## ជំពូកទី ៨

## អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

**មាត្រា ២១.-**

អគ្គនាយកដ្ឋានសុរិយោដី ភូមិសាស្ត្រ មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារៈ

- ជាសេនាធិការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ លើកិច្ចការសុរិយោដី និង ភូមិសាស្ត្រ
- សិក្សាស្រាវជ្រាវ កសាងគំរោងលិខិតបទដ្ឋានទាំងឡាយ ដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងប្រើប្រាស់ដីធ្លី
- កសាងទិសដៅ និងផែនការ ដើម្បីបំរើការងារលើវិស័យសុរិយោដី និង ភូមិសាស្ត្រ
- ធ្វើការវាស់វែង និង គូរផែនទីសុរិយោដី
- ចេញប័ណ្ណសំគាល់ដីធ្លីទូទាំងព្រះរាជាណាចក្រកម្ពុជា
- ធ្វើការអភិរក្សសុរិយោដី និងធ្វើអធិការកិច្ចក្នុងតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- កំណត់ព្រំប្រទល់ក្បាលដី
- អភិរក្សទ្រព្យសម្បត្តិរដ្ឋ
- សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញដល់មន្ត្រីរាជការក្រោមឱវាទ
- ធ្វើជាសេនាធិការអោយក្រសួង ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងបណ្តា ប្រទេសនានា លើផ្នែកបច្ចេកទេស វិទ្យាសាស្ត្របំរើអោយវិស័យសុរិយោដី និងភូមិសាស្ត្រ
- សហការជាមួយក្រសួង និង ស្ថាប័ននានា ក្នុងការគ្រប់គ្រង និង ប្រើប្រាស់ដីធ្លី។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករង ជាជំនួយការតាមការចាំបាច់។

អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ៥ គឺ :

- នាយកដ្ឋានគ្រប់គ្រងដីធ្លី

- នាយកដ្ឋានអធិការកិច្ចភូមិបាល
- នាយកដ្ឋានបច្ចេកទេស
- នាយកដ្ឋានអភិរក្សសុរិយោដី
- នាយកដ្ឋានភូមិសាស្ត្រ ។

**មាត្រា ២២.-**

នាយកដ្ឋានគ្រប់គ្រងដីធ្លី មានតួនាទី និង ភារកិច្ច ដូចតទៅ :

- សិក្សាស្រាវជ្រាវច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធនឹងដីធ្លី
- ចងក្រងគោលការណ៍វិធានការ និង ការណែនាំពាក់ព័ន្ធនឹងការងារសុរិយោដី
- កសាងផែនការ និង កម្មវិធីការងារសុរិយោដី
- លើកគំរោងសហប្រតិបត្តិការ លើវិស័យបច្ចេកទេសវិទ្យាសាស្ត្រ
- កំណត់ចំណាត់ថ្នាក់ដី និង វាយតំលៃដី
- លើកសំណើអំពីនយោបាយដីធ្លី និង បដិរូបដីធ្លី ។

នាយកដ្ឋានគ្រប់គ្រងដីធ្លី ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាម ការចាំបាច់ ។

**មាត្រា ២៣.-**

នាយកដ្ឋានអធិការកិច្ចភូមិបាល មានតួនាទី និង ភារកិច្ច ដូចតទៅ :

- ត្រួតពិនិត្យការអនុវត្តច្បាប់ គោលការណ៍ ការណែនាំ តាមបណ្តាអង្គភាពចំណុះ អគ្គនាយកដ្ឋាន ។
- ត្រួតពិនិត្យការងារបច្ចេកទេស ក្នុងការកំណត់វិធីសាស្ត្រវាស់វែង ការគណនាការងារសុរិយោដី ខេត្ត-ក្រុង និងស្រុក-ខណ្ឌ
- ត្រួតពិនិត្យការកាន់កាប់ឯកសារសុរិយោដី
- ត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុ ។

នាយកដ្ឋានអធិការកិច្ចភូមិបាល ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ២៤.-**

នាយកដ្ឋានអភិរក្សសុរិយោដី មានតួនាទី និង ភារកិច្ច ដូចតទៅ:

- កាន់កាប់ និង គ្រប់គ្រងឯកសារសុរិយោដី
- ពិនិត្យ ផ្ទៀងផ្ទាត់ សំណុំលិខិតសញ្ញាផ្សេងៗ ពាក់ព័ន្ធនឹងអចលនវត្ថុ
- ធ្វើការអភិរក្សទ្រព្យសម្បត្តិរដ្ឋ
- ចុះបញ្ជីដីធ្លី ធ្វើលេខាចារឹក នឹងចរន្តការ រាល់ការវិវត្តអំពីលក្ខណៈរូប និង គតិយុត្តិរបស់ អចលនវត្ថុ
- រក្សាឯកសារ និង ប័ណ្ណសារដ្ឋានភូមិបាល
- ផ្តល់ពតិមានដីធ្លី ។

នាយកដ្ឋានអភិរក្សសុរិយោដីដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការ តាមការចាំបាច់។

**មាត្រា ២៥.-**

នាយកដ្ឋានបច្ចេកទេស មានតួនាទី និង ភារកិច្ច ដូចតទៅ :

- សិក្សា កំណត់ វិធីសាស្ត្រវាស់វែង និង ស្តង់ដារបច្ចេកទេស
- ណែនាំ បច្ចេកទេស ការងារសុរិយោដីខេត្ត-ក្រុង
- គ្រប់គ្រងទិន្នន័យដីធ្លី តាមប្រព័ន្ធសុរិយោដីទំនើប
- ធ្វើការវាស់វែង កំណត់ព្រំក្បាលដី និង គូរប្លង់ក្បាលដី
- បកស្រាយរូបថត ធ្វើអត្តសញ្ញាណក្បាលដី
- សិក្សា និង កំណត់នីតិវិធី នៃការកសាងប្លង់សុរិយោដី។

នាយកដ្ឋានបច្ចេកទេស ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាម ការចាំបាច់។

**មាត្រា ២៦.-**

**នាយកដ្ឋានភូមិសាស្ត្រ មានតួនាទី និង ភារកិច្ចដូចតទៅ :**

- ចាត់តាំង អនុវត្តភារកិច្ចវាស់វែង ដាំបង្គោលបណ្តាញត្រីកោណ និង គូរផែនទីគោលជាមូលដ្ឋានទូទាំងប្រទេស
- គ្រប់គ្រងផែនទីគ្រប់ប្រភេទរបស់ព្រះរាជាណាចក្រកម្ពុជា សំដៅអោយឯកភាពទូទាំងប្រទេស
- ចាត់តាំង ស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសវាស់វែង ថតរូប គូរ និង បោះពុម្ពផ្សាយ ផែនទីគ្រប់ប្រភេទ
- សហការជាមួយនាយកដ្ឋានបុគ្គលិក និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះ បណ្តាលមន្ត្រីបុគ្គលិក ផ្នែកភូមិសាស្ត្រ
- ធ្វើជាសេនាធិការអោយគណៈកម្មការ កំណត់ព្រំដែនរាជរដ្ឋាភិបាល អំពីការងារខណ្ឌព្រំសីមា និងបោះបង្គោល ព្រំដែនរដ្ឋ
- ធ្វើជាសេនាធិការអោយរាជរដ្ឋាភិបាលក្នុងការវាស់វែង កំណត់ និងកែតំរូវព្រំប្រទល់រដ្ឋបាល ក្នុងប្រទេស
- ជាមជ្ឈមណ្ឌលប្រមូលផ្តុំពត៌មានភូមិសាស្ត្រ និង ធ្វើសកម្មភាពចាត់ចែងការងារខាងវិទ្យាសាស្ត្រ វាស់វែង និងផ្តល់ប្រព័ន្ធពត៌មានភូមិសាស្ត្រ
- បង្កើតប្រព័ន្ធពត៌មានភូមិសាស្ត្រជាតិ ឯកភាពគ្នាមួយសំរាប់ព្រះរាជាណាចក្រកម្ពុជា
- កសាងផែនទី ជាពិសេសផែនទីគោល ផែនទីឋានលេខានៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រង និង ត្រួតពិនិត្យ ក្នុងការបោះពុម្ព ផលិតផែនទីគ្រប់ប្រភេទសំរាប់ធ្វើអាជីវកម្ម។

នាយកដ្ឋានភូមិសាស្ត្រ ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានជាជំនួយការតាម ការចាំបាច់។

## ជំពូកទី ៩

## មន្ទីរពិសោធន៍

**មាត្រា ២៧.-**

**មន្ទីរពិសោធន៍ មានតួនាទី និង ភារកិច្ចដូចតទៅ :**

- ត្រួតពិនិត្យ និង ទទួលពិសោធន៍រាល់បណ្តុំសំភារ:សំណង់ គ្រឿងផ្គុំសំណង់ និង ភូគព្ភសាស្រ្ត ទីតាំងសាងសង់ របស់ក្រសួងអតិថិជន
- ស្រាវជ្រាវបង្កើតសំភារះសំណង់ ដែលប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក
- ធ្វើរបាយការណ៍បច្ចេកទេស អំពីលទ្ធផលនៃការពិសោធន៍
- ណែនាំ និង ត្រួតពិនិត្យកិច្ចការបច្ចេកទេសពិសោធន៍សំណង់ដល់មន្ទីរពិសោធន៍នានា។

មន្ទីរពិសោធន៍ដឹកនាំដោយប្រធានមួយរូប ថ្នាក់ស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធាន ជា ជំនួយការ តាមការចាំបាច់។

## ជំពូកទី ១០
## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា ២៨.-**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចជាសេនាធិការអោយក្រសួងក្នុងការងារ:

- រៀបចំផែនការ និង កម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវះ ស្របតាមនយោបាយ របស់ក្រសួង
- បណ្តុះបណ្តាលមុខជំនាញបច្ចេកទេស បច្ចេកទេសវិទ្យាទំនើប ៗ
- បង្រៀនពតិមានវិទ្យា ការគ្រប់គ្រងពតិមានតាមប្រព័ន្ធកុំព្យូទ័រទាក់ទងមុខជំនាញរបស់ក្រសួង
- ធ្វើវិក្រឹតការ សុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង
- ផ្សព្វផ្សាយ អប់រំ ណែនាំ អំពីនយោបាយ ច្បាប់ បទប្បញ្ញត្តិ និង បច្ចេកទេសពាក់ព័ន្ធ នឹងការងាររៀបចំដែនដី នគរូបនីយកម្មសំណង់ សុរិយោដី និង ភូមិសាស្ត្រ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការណែនាំ ត្រួតពិនិត្យការងារបណ្តុះបណ្តាល បច្ចេកទេស វិជ្ជាជីវ: នៅសាលាឯកជនពាក់ព័ន្ធនឹងការរៀបចំ ដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និង ភូមិសាស្ត្រ
- ធ្វើជាសេនាធិការអោយក្រសួងក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែន រដ្ឋាភិបាលសហគមន៍មូលដ្ឋាន និង បណ្តាប្រទេសនានា។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវ: ដឹកនាំដោយប្រធានមួយរូបថ្នាក់ស្មើប្រធាននាយកដ្ឋាន និង មានអនុប្រធានជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ១១
## គ្រឹះស្ថាន និង សហគ្រាសក្រោមឱវាទ

**មាត្រា ២៩.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានគ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទ ដូចខាងក្រោម :

- សហគ្រាសសំណង់ភ្នំពេញ
- សហគ្រាសគ្រឿងចក្រសំណង់ជួសជុល
- សហគ្រាសសិក្សាស្រាវជ្រាវគូរប្លង់
- សហគ្រាសសំណង់កំពង់ចាម
- សហគ្រាសសំភារះដឹកជញ្ជូន
- រោងចក្រអិដ្ឋពណិ
- រោងចក្រអារឈើ
- រោងចក្រឡអិដ្ឋ
- រោងចក្រហ្វីប្រូស៊ីម៉ង់ត៍

សហគ្រាសទាំងនេះ ឋិតនៅក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួង និង ក្រោមការគ្រប់គ្រងរបស់ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច ។

## ជំពូកទី ១២

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៣០.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមក្របខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ វិច្ឆិកា ១៩៩៥ ស្តីពីការបង្កើត ស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី ១៣

## អង្គភាពមូលដ្ឋាន

**មាត្រា ៣១.-**

នៅតាមខេត្ត ក្រុងនីមួយៗ មានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី និង នៅតាមខណ្ឌស្រុកនីមួយៗ មានការិយាល័យរៀបចំដែនដី សំណង់ និង ភូមិបាល ដែលទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពការងារ របស់ក្រសួង។

## ជំពូកទី ១៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣២.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនៅរដ្ឋបាលថ្នាក់កណ្តាល ចាប់ពីថ្នាក់ក្រោម នាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

**មាត្រា ៣៣.-**

ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធ នឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ននៃស្ថាប័នដទៃ ទាំងនោះ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង ប្រធានស្ថាប័នទាំងនោះ។

**មាត្រា ៣៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួន ។

**មាត្រា ៣៦.-**

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អំពីយើង

- ក្រសួង
- អគ្គនាយកដ្ឋាន
- មន្ទីរ ខេត្ត ក្រុង
- ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- គណៈកម្មការដោះស្រាយបាតុភាពដីធ្លី
- គណៈកម្មការជាតិដីសម្បទានសង្គមកិច្ច
- គំរោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លី

## មន្ទីរ ខេត្ត ក្រុង

ទំនាក់ទំនង ៖

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ

| | | |
|---|---|---|
| លោក ឆាយ ឫទ្ធីសែន | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ | 011 956 947 |




| | | | |
|---|---|---|---|
| បន្ទាយមានជ័យ | លោក លី សារី | ប្រធានមន្ទីរ | 012 836 896 |
| បាត់ដំបង | លោក ងួន រតនៈ | ប្រធានមន្ទីរ | 012 914 691 |
| កំពង់ចាម | លោក ឌី កាលីនី | ប្រធានមន្ទីរ | 012 807 262 |
| កំពង់ឆ្នាំង | លោក តែវ សៀងសោភ័ណ | ប្រធានមន្ទីរ | 012832 155 |

| | | | |
|---|---|---|---|
| កំពង់ស្ពឺ | លោក ឡាយ គឹមហ៊ាង | ប្រធានមន្ទីរ | 016 656 667 |
| កំពង់ធំ | លោក ឌិត ធន | ប្រធានមន្ទីរ | 012 716 319 |
| កំពត | លោក ប៉ាង ប៉ុណ្ណារដ្ឋ | ប្រធានមន្ទីរ | 012 932 414 |
| កណ្តាល | លោក ឈឹម គន | ប្រធានមន្ទីរ | 012 399 746 |
| កែប | លោក មៅ សុខា | ប្រធានមន្ទីរ | 012 820 844 |
| កោះកុង | លោក ហាក់ ហៀន | ប្រធានមន្ទីរ | 016 684 333 |
| ក្រចេះ | លោក ម៉ាន់ សុផាត | ប្រធានមន្ទីរ | 012 843 600 |
| មណ្ឌលគីរី | លោកស្រី ម៉េង វ៉ែន | ប្រធានមន្ទីរ | 012 960 038 |
| ឧត្តរមានជ័យ | លោក ឡៅ ឆន | ប្រធានមន្ទីរ | 012 846 849 |
| ប៉ៃលិន | លោក តាន់ តែម | ប្រធានមន្ទីរ | 012 1 734 356 |
| ព្រះវិហារ | លោក គង់ សោភ័ណ | ប្រធានមន្ទីរ | 092 969 821 |
| ព្រៃវែង | លោក នៃ សុផល | ប្រធានមន្ទីរ | 012 892 145 |
| ពោធិ៍សាត់ | លោក ផៃ សេងហ៊ួត | ប្រធានមន្ទីរ | 012 520 060 |
| រតនៈគីរី | លោក ទឹម ស៊ីណាត | ប្រធានមន្ទីរ | 012 980 377 |
| សៀមរាប | លោក សៃ សាមុត | ប្រធានមន្ទីរ | 012 898 929 |
| កំពង់សោម | លោក សូ សុខ | ប្រធានមន្ទីរ | 012 234 200 |
| ស្ទឹងត្រែង | លោក ជួ ជិនសុធា | ប្រធានមន្ទីរ | 012 777 991 |
| ស្វាយរៀង | លោក បៀយ យ៉ា | ប្រធានមន្ទីរ | 011 443 026 |
| តាកែវ | លោក សុក សិត | ប្រធានមន្ទីរ | 011 821 574 |

## រចនាសម្ព័ន្ធ




Comment this page[kh]

No. 771-773, Monivong Boulevard, Boeng Trabek,Chamcarmon, Phnom Penh, Kingdom of Cambodia
© 2007 MLMUPC, supported by GTZ.

## អំពីយើង



### អគ្គនាយកដ្ឋាន រដ្ឋបាល

#### រចនាសម្ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាល




ទំនាក់ទំនង ៖

**អគ្គនាយកដ្ឋានរដ្ឋបាល**

| | | | |
|---|---|---|---|
| លោក កែវ កុសល | អគ្គនាយករដ្ឋបាលស្តីទី | gdadmin-mlmupc@camnet.com.kh | 023 881 232 |
| លោក កែវ វ៉ូហេ្យ | អគ្គនាយករង | | 012 533 535 |
| លោកស្រី នន់ ភានី | អគ្គនាយករង | | 092 842 105 |
| លោក ឡាយ ផល្លីម | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ទទួលបន្ទុកការងាររួម | | 012 867 070 |

### ភារកិច្ច និងអាណត្តិ

អត្ថបទខាងក្រោមនេះដកស្រង់ចេញពីប្រកាលេខ ៦៧ ប្រក/ដ.ន.ស របស់ក្រសួង ដែលកំណត់អំពីតួនាទី និងភារកិច្ចរបស់គ្រប់នាយកដ្ឋាន

ក្រោមឱវាទក្រសួង ដ.ន.ស (សូមមើលក្នុងរចនាសម្ព័ន្ធ របស់ក្រសួងត្រង់ប្រកាសទី ៤ ដល់ទី៨ )

Comment this page[kh]


© 2007 MLMUPC, supported by GTZ.

អំពីយើង

- ក្រសួង
- អគ្គនាយកដ្ឋាន
  - អគ្គនាយកដ្ឋាន រដ្ឋបាល
  - អគ្គនាយកដ្ឋាន សុរិយោដី និង ភូមិសាស្ត្រ
  - អគ្គនាយកដ្ឋាន រៀបចំដែនដី និង នគរូបនីយកម្ម
  - អគ្គនាយកដ្ឋាន សំណង់
- មន្ទីរ ខេត្ត ក្រុង
- ក្រុមប្រឹក្សា គោលនយោបាយដីធ្លី
- គណៈកម្មការដោះស្រាយ បាតុភាពដីធ្លី
- គណៈកម្មការជាតិ ដីសម្បទានសង្គមកិច្ច
- គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

# អគ្គនាយកដ្ឋាន សុរិយោដី និង ភូមិសាស្ត្រ

រចនាសម្ព័ន្ធ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ




ទំនាក់ទំនង ៖

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

| | | |
|---|---|---|
| ឯកឧត្តម **លឹម វ៉ាន់** | អគ្គនាយក | 016 838 493,023 880 744 |
| លោក **សៀក វណ្ណា** | អគ្គនាយករង | 017 907 778 |
| លោក **សរ សុវណ្ណ** | អគ្គនាយករង | 012 897 429 |
| លោក **ឆិត សេដ្ឋា** | អគ្គនាយករង | 016 859 579 |
| លោក **ហុយ ផាប់** | អគ្គនាយករង | 016 250 343 |

## ភារកិច្ច និងអាណត្តិ

អត្ថបទខាងក្រោមនេះដកស្រង់ចេញពីប្រកាសលេខ ៦៤ ប្រក/ដ.ន.ស របស់ក្រសួង ដែលកំណត់អំពីតួនាទី និងភារកិច្ចរបស់គ្រប់នាយកដ្ឋាន

ក្រោមឪវាទក្រសួង ដ.ន.ស (សូមមើលក្នុងរចនាសម្ព័ន្ធ របស់ក្រសួង ត្រង់ប្រកាសទី **15** ដល់ទី **19** )

Comment this page[kh]

No. 771-773, Monivong Boulevard, Boeng Trabek,Chamcarmon, Phnom Penh, Kingdom of Cambodia
© 2007 MLMUPC, supported by GTZ.

## អំពីយើង

- ក្រសួង
- អគ្គនាយកដ្ឋាន
  - អគ្គនាយកដ្ឋាន រដ្ឋបាល
  - អគ្គនាយកដ្ឋាន សុរិយោដី និង ភូមិសាស្ត្រ
  - អគ្គនាយកដ្ឋាន រៀបចំដែនដី និង នគរូបនីយកម្ម
  - អគ្គនាយកដ្ឋាន សំណង់
- មន្ទីរ ខេត្ត ក្រុង
- ក្រុមប្រឹក្សា គោលនយោបាយដីធ្លី
- គណ:កម្មការដោះស្រាយ បាតុភាពដីធ្លី
- គណ:កម្មការជាតិ ដីសម្បទានសង្គមកិច្ច
- គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

# អគ្គនាយកដ្ឋាន រៀបចំដែនដី និង នគរូបនីយកម

រចនាសម្ព័ន្ធ អគ្គនាយកដ្ឋាន រៀបចំដែនដី និងនគរូបនីយកម្ម




អាសយដ្ឋាន:

អគ្គនាយកដ្ឋាន រៀបចំដែនដី និងនគរូបនីយកម្ម

| | | | |
|---|---|---|---|
| ឯកឧត្តមបណ្ឌិត ឧុច វនទីត្ | អគ្គនាយក | 023 217 027 | 012 940 203, 023 880 862 |
| លោក សួស សុផល | អគ្គនាយករង | | 012 980 142 |
| លោក ប្រាក់ អង្គារ៉ា | អគ្គនាយករង | | 012 869 377 |

## ភារកិច្ច និងអាណត្តិ

អត្ថបទខាងក្រោមនេះដកស្រង់ចេញពីប្រកាសលេខ ៦៨ ប្រក/ដ.ន.ស របស់ក្រសួង ដែលកំណត់អំពីតួនាទី និងភារកិច្ចរបស់គ្រប់នាយកដ្ឋាន ក្រោមឪវាទក្រសួង ដ.ន.ស (សូមមើលក្នុងរចនាសម្ព័ន្ធ របស់ក្រសួងត្រង់ប្រកាសទី 09 ដល់ទី 11)

Comment this page[kh]


© 2007 MLMUPC, supported by GTZ.

អំពីយើង

⊞ ក្រសួង
⊟ អគ្គនាយកដ្ឋាន
- អគ្គនាយកដ្ឋាន រដ្ឋបាល
- អគ្គនាយកដ្ឋាន សុរិយោដី និង ភូមិសាស្ត្រ
- អគ្គនាយកដ្ឋាន រៀបចំដែនដី និង នគរូបនីយកម្ម
- អគ្គនាយកដ្ឋាន សំណង់

⊞ មន្ទីរ ខេត្ត ក្រុង
⊞ ក្រុមប្រឹក្សា គោលនយោបាយដីធ្លី
⊞ គណៈកម្មការដោះស្រាយ បាតុភាពដីធ្លី
⊞ គណៈកម្មការជាតិ ដីសម្បទានសង្គមកិច្ច
⊞ គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

# អគ្គនាយកដ្ឋាន សំណង់

រចនាសម្ព័ន្ធ អគ្គនាយកដ្ឋាន សំណង់




ទំនាក់ទំនង ៖

អគ្គនាយកដ្ឋាន សំណង់

| | | |
|---|---|---|
| ឯកឧត្តម **អ៊ឹម ចំរុង** | អគ្គនាយក | 012 815 335, 023 880 665 |
| លោក **សែ សាមុត** | អគ្គនាយករង | 012 898 929 |
| លោក **ហ៊ុយ ណារ៉ា** | អគ្គនាយករង | 012 508 311 |
| លោក **ប៉ាក់ ចាន់ផល** | អគ្គនាយករង | 012 548 885 |

## ភារកិច្ច និងអាណត្តិ

អត្ថបទខាងក្រោមនេះដកស្រង់ចេញពីប្រកាសលេខ ៦៨ ប្រក/ដ.ន.ស របស់ក្រសួងដែលកំណត់អំពីតួនាទី និងភារកិច្ចរបស់គ្រប់ នាយកដ្ឋាន ក្រោមឱវាទក្រសួង ដ.ន.ស (សូមមើលក្នុងរចនាសម្ព័ន្ធ របស់ក្រសួងត្រង់ប្រកាសទី **12** ដល់ទី **14** )

Comment this page[kh]

No. 771-773, Monivong Boulevard, Boeng Trabek,Chamcarmon, Phnom Penh, Kingdom of Cambodia
© 2007 MLMUPC, supported by GTZ.




Sarath, Organization chart of MLMUPC

# អង្គការលេខរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ប្រធាននាយកដ្ឋាន**

សរ សាមេធា

Tele: 017 747 603

**អនុប្រធាននាយកដ្ឋាន**

១-ក្រេត វិសាលលទ្ធា
Tel: 012 863 366

២- ម៉ៅ ឧស្សាហ៍
Tel: 012 958 537

៣- អ៊ុង សួនស្មី
Tel: 011 905 555

**ប្រធានការិយាល័យទី ១**

គុន ចិន្តាមណី
Tel: 016 919 157

១-ថេង លាង :អនុប្រធាន
Tel: 012 729 967

២-សំ រក្សា :អនុប្រធាន
Tel: 017 876 598
Tel :011 978 304

**ប្រធានការិយាល័យទី ២**

យួន សុជាតិ
Tel: 015 619 007

១-ចក់ ឡឿន :អនុប្រធាន
Tel: 016 661 788

២- ហេង វិសាល មន្ត្រី
Tel: 015 999972

**ប្រធានការិយាល័យទី ៣**

អ៊ុត សុផា
Tel: 012 858 696

១-អេ ម៉ុនថេត : មន្ត្រី
Tel: 012 355 937

២-សុខ ម៉ារ៉ា : មន្ត្រី
Tel: 016 705 171

**ប្រធានការិយាល័យទី ៤**

ឡុង វណ្ណា
Tel: 012 638 189

១-ម៉ៃ វណ្ណា : អនុប្រធាន
Tel: 012 200 373

២-ផូរ កញ្ញាទេពី : មន្ត្រី
Tel: 012 693 773

KINGDOM OF CAMBODIA

Ministry of Land Management,
Urban Planning and Construction

ខ្មែរ | Khmer Fo

Email:
Password:
login
Search: g

Home News Projects Contact Document - Library Glossary Links

## About Us

- The Ministry
- General Departments
- Provincial and Municipal Departments
- Council for Land Policy
- Cadastral Commission
- National Social Land Concession Committee
- Land Managemnet and Administration Project

## Provincial and Municipal Departments

### Municipal Departments

**Municipal Department of Land Management, Urban Planning and Construction, Phnom Penh**

| | | |
|---|---|---|
| Mr. Chhay Rithysen | Chief of PLMUPC | 011956947 |

### Provincial Departments

Provincial Departments are located in the province capital as show below:




**Provincial Departments**

| | | | |
|---|---|---|---|
| Bantheay Meanchey | Mr. Ly Sary | Chief of PLMUPC | 012 836 869 |
| Battambang | Mr. Nguon Rattanak | Chief of PLMUPC | 012 914 691 |
| Kampong Cham | Mr. Dy Kaliny | Chief of PLMUPC | 012 807 262 |
| Kampong Chhnang | Mr. Keo Seurn Sophan | Chief of PLMUPC | 012 832 155 |

| | | | |
|---|---|---|---|
| Kampong Speu | Mr. Lay Kim Heang | Chief of PLMUPC | 016 656 667 |
| Kampong Thom | Mr. Dit Thorn | Chief of PLMUPC | 012 716 319 |
| Kampot | Mr. Pang Ponnarath | Chief of PLMUPC | 012 932 414 |
| Kandal | Mr. Chhim Kan | Chief of PLMUPC | 012 399 746 |
| Kep | Mr. Vao Sokha | Chief of PLMUPC | 012 820 844 |
| Koh Kong | Mr. Hak Heurn | Chief of PLMUPC | 016 684 333 |
| Kratie | Mr. Man Sophat | Chief of PLMUPC | 012 843 600 |
| Mondulkiri | Mrs. Beng Ren | Chief of PLMUPC | 012 960 038 |
| Oddar Meanchey | Mr. Lao Chhan | Chief of PLMUPC | 012 846 849 |
| Pailin | Mr. Tan Tem | Chief of PLMUPC | 012 1 734 356 |
| Preah Vihear | Mr. Kong Sophoan | Chief of PLMUPC | 092 969 821 |
| Prey Veng | Mr. Ney Sophal | Chief of PLMUPC | 012 892 145 |
| Pursat | Mr. Pey Seng Hout | Chief of PLMUPC | 012 520 060 |
| Rattanakiri | Mr. Tim Sinat | Chief of PLMUPC | 012 980 377 |
| Siem Reap | Mr. Se Samuth | Chief of PLMUPC | 012 898 929 |
| Preah Sihanouk | Mr. So Sok | Chief of PLMUPC | 012 234 200 |
| Steung Treng | Mr. Chou chinsotha | Chief of PLMUPC | |
| Svay Rien | Mr. Buoy Ya | Chief of PLMUPC | 011 443 026 |
| Takeo | Mr. Sok Sith | Chief of PLMUPC | 011 821 574 |

**Organisational Structure:**




Comment this page

No. 771-773, Monivong Boulevard, Boeng Trabek,Chamcarmon, Phnom Penh, Kingdom of Cambodia

© 2007 MLMUPC, supported by GTZ.